ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**
**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខៈ ២៩៥
ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣
សាលក្រមរដ្ឋប្បវេណីលេខៈ៥៨(ង)/៣៥២
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ
នៅសាលសវនាការលេខៈ ក១ នៃសាលាដំបូងខេត្តសៀមរាប
បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ៈ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣
កាលបរិច្ឆេទប្រកាសសាលក្រមៈ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈ ចៅក្រមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ឋានៈ ក្រឡាបញ្ជី

**ដើមចោទៈ**

ឈ្មោះ [redacted]សុខគីម ភេទស្រី កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៨០ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted]ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៥ មានអាសយដ្ឋាន[redacted]។

**ចុងចម្លើយៈ**

ឈ្មោះ [redacted] សំបូរ ភេទស្រី កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៨៧ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted]មានអាសយដ្ឋានស្ថិតនៅ[redacted]។

អ្នកតំណាងដោយអាណត្តិៈ

១-លោកមេធាវី [redacted] ជាមេធាវីនៃក្រុមមេធាវី[redacted]។

២-លោកមេធាវី [redacted] មានអាសយដ្ឋានស្ថិតនៅ[redacted]។

**ក-ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឲ្យតុលាការចេញៈ**

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សំបូរ សងប្រាក់ដើមមកឲ្យដើមចោទឈ្មោះ [redacted]សុខគីម រួមមានៈ

១-១-ប្រាក់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១)។

១-២-ប្រាក់ចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់



Scanned with CamScanner

បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១)។

១-៣-ប្រាក់ចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២)។

១-៤-ប្រាក់ចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២)។

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សំបូរ សងការប្រាក់នៃប្រាក់ដើមមកឲ្យដើមចោទ ដែលការប្រាក់មានដូចខាងក្រោម៖

២-១-ការប្រាក់ចំនួន ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ១០០.០០០$ (មួយរយពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-២-ការប្រាក់ចំនួន ៣%(បីភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-៣-ការប្រាក់ចំនួន ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ៥០.០០០$ (ហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-៤-ការប្រាក់ចំនួន ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ៥៦.០៧០$ (ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សំបូរ សងថ្លៃខូចខាត និងសំណងជម្ងឺចិត្តចំនួន ៥០.០០០.០០០៛ (ហាសិបលានរៀល)។

៤-សុំអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុចទី១(១-១, ១-២, ១-៣ និង១-៤)។

**ខ-ដំណើររឿងក្តី និងចំណុចវិវាទ**

**ខ-១-ការពន្យល់ត្រួសៗអំពីដំណើររឿងក្តី**

តាមពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ឃើញថា ចុងចម្លើយបានខ្ចីប្រាក់ដើមចោទចំនួន ០៤លើក ដោយលើកទី១ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក), លើកទី២ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក), លើកទី៣ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ចំនួន ៥០.០០០$(ហាសិបពាន់ចិតសិបដុល្លារអាមេរិក) និងលើកទី៤ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) សរុបមានចំនួន ៣៥៦.០៧០$(បីរយហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក)។

**ខ-២-អង្គហេតុដែលគ្មានវិវាទ**

គ្មាន។

**ខ-៣-ចំណុចវិវាទ**

តើការទាមទារប្រាក់ចំនួន ៣៥៦.០៧០$(សាមសិបប្រាំម៉ឺនប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) របស់ដើមចោទចំពោះចុងចម្លើយត្រឹមត្រូវដែរ ឬទេ?

**ខ-៤-ការអះអាងរបស់ដើមចោទ**



Scanned with CamScanner

ឈ្មោះ [redacted] សុខគីម ជាដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួននៅរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ទុកជាបានការដដែល ដោយមូលហេតុក៏ដូចអង្គហេតុនៃការទាមទារមានដូចខាងក្រោម:

**ការទាមទារចំណុចទី១**

ឈ្មោះ [redacted] សំបូរ បានខ្ចីប្រាក់ពីខ្លួន ហើយចុងចម្លើយក៏បានបើកប្រាក់ប្រើប្រាស់រួចហើយ ដែលមានប្រាក់សរុបទាំងអស់មានចំនួន ៣៥៦.០៧០$(បីរយហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) ហើយទឹកប្រាក់នេះចុងចម្លើយបានខ្ចីពីខ្លួនចំនួន ០៤(បួន)លើក មានដូចខាងក្រោម៖

**លើកទី១៖** ប្រាក់ដើមចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។ ចុងចម្លើយត្រូវបង់ប្រាក់មកឲ្យខ្លួនជារៀងរាល់ខែ។ នៅក្នុងការអនុវត្តកិច្ចសន្យាខាងលើ ចុងចម្លើយមិនបានបង់ប្រាក់ដើមមកឲ្យខ្លួននោះទេ ធ្វើឲ្យប្រាក់ដើមដែលចុងចម្លើយនៅជំពាក់មានចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក)ដដែល។

**លើកទី២៖** ប្រាក់ដើមចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។ ចុងចម្លើយត្រូវបង់ប្រាក់មកឲ្យខ្លួនជារៀងរាល់ខែ ប៉ុន្តែចុងចម្លើយមិនបានបង់ប្រាក់ដើមមកឲ្យខ្លួនទេ ធ្វើឲ្យប្រាក់ដែលនៅជំពាក់មានចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក)ដដែល។

**លើកទី៣៖** ប្រាក់ដើមចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២។ ចុងចម្លើយត្រូវបង់ប្រាក់មកឲ្យខ្លួនជារៀងរាល់ខែ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចបង់ប្រាក់មកឲ្យនោះទេ ធ្វើឲ្យប្រាក់ដើមដែលនៅជំពាក់មានចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក)ដដែល។

**លើកទី៤៖** ប្រាក់ដើមចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។ ចុងចម្លើយត្រូវបង់ប្រាក់មកឲ្យខ្លួនជារៀងរាល់ខែ ប៉ុន្តែចុងចម្លើយមិនបានបង់ប្រាក់មកឲ្យខ្លួននោះទេ ធ្វើឲ្យប្រាក់ដើមដែលនៅជំពាក់មានចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក)ដដែល។

សរុបទាំង០៤(បួន)កិច្ចសន្យាខ្ចីបរិភោគខាងលើ ប្រាក់ដើមដែលចុងចម្លើយនៅជំពាក់មានចំនួន ៣៥៦.០៧០$(បីរយហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក)។ ហេតុនេះ បានជាខ្លួនទាមទារឲ្យចុងចម្លើយសងប្រាក់ខាងលើនេះត្រឡប់មកវិញ។

**ការទាមទារចំណុចទី២**

១-តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ នៅត្រង់ប្រការ២ ចុងចម្លើយនិងខ្លួនបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ ស្មើនឹង ២.៥០០$(ពីរពាន់ប្រាំរយដុល្លារអាមេរិក) នៃប្រាក់ដែលបានខ្ចី ដោយកំណត់រយៈពេលខ្ចីចំនួន ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។ នៅក្នុងការបង់ការប្រាក់នេះ ចុងចម្លើយមិនបានបង់ការប្រាក់មកឲ្យខ្លួននោះទេ ចាប់តាំងពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១មក។



Scanned with CamScanner

ហេតុនេះ ទើបខ្លួនទាមទារឲ្យចុងចម្លើយបង់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន។

២-តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ នៅត្រង់ប្រការ២ ចុងចម្លើយ និងខ្លួនបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ៣%(បីភាគរយ)ក្នុងមួយខែ ស្មើនឹង ៤.៥០០$(បួនពាន់ប្រាំរយដុល្លារអាមេរិក) នៃប្រាក់ដែលបានខ្ចី ដោយកំណត់រយៈពេលខ្ចីចំនួន ០២(ពីរ)ខែ គិតចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២។ នៅក្នុងការបង់ការប្រាក់នេះ ចុងចម្លើយមិនបានបង់ការប្រាក់មកឲ្យខ្លួននោះទេ ចាប់តាំងពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ មក។

ហេតុនេះ ទើបខ្លួនទាមទារឲ្យចុងចម្លើយបង់ការប្រាក់តាមអត្រា ៣%(បីភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន។

៣-តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ នៅត្រង់ប្រការ២ ចុងចម្លើយ និងខ្លួនបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ ស្មើនឹង ១.២៥០$(មួយពាន់ពីររយហាសិបដុល្លារអាមេរិក) លើប្រាក់ដែលបានខ្ចី ដោយកំណត់រយៈពេលខ្ចីចំនួន ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣។ នៅក្នុងការបង់ការប្រាក់នេះ ចុងចម្លើយមិនបានបង់ការប្រាក់មកឲ្យខ្លួននោះទេ ចាប់តាំងពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ មក។

ហេតុនេះ ទើបខ្លួនទាមទារឲ្យចុងចម្លើយបង់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន។

៤-តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ នៅត្រង់ប្រការ២ ចុងចម្លើយ និងខ្លួនបានព្រមព្រៀងគ្នាកំណត់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ ស្មើនឹង ១.៤០១,៧៥$(មួយពាន់បួនរយមួយក្បៀសចិតសិបប្រាំដុល្លារអាមេរិក) នៃប្រាក់ដែលបានខ្ចី ដោយកំណត់រយៈពេលខ្ចីចំនួន ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣។ នៅក្នុងការបង់ការប្រាក់នេះ ចុងចម្លើយមិនបានបង់ការប្រាក់មកឲ្យខ្លួននោះទេ ចាប់តាំងពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ មក។

ហេតុនេះ ទើបខ្លួនទាមទារឲ្យចុងចម្លើយបង់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួចគ្រប់ចំនួន។

**ការទាមទារចំណុចទី៣**

ដោយសារតែចុងចម្លើយមិនព្រមសងប្រាក់ដែលបានខ្ចីខ្លួនមកឲ្យខ្លួនវិញ។

**ការទាមទារចំណុចទី៤**

ដោយសារតែចុងចម្លើយមិនព្រមសងប្រាក់ដែលបានខ្ចីខ្លួនមកឲ្យខ្លួនវិញ ហើយការខ្ចីប្រាក់នេះ ក៏មាន



Scanned with CamScanner

ការបង្កើតកិច្ចសន្យាច្បាស់លាស់ដែរ។

**ខ-៥-ការអះអាងរបស់ចុងចម្លើយ**

លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ បានធ្វើសេចក្ដីថ្លែងការណ៍ថា: កូនក្ដីខ្លួន និងដើមចោទបានចូលហ៊ុនរកស៊ីជាមួយគ្នា ដោយបានទិញដីទំហំ ៨០(ប៉ែតសិប)ហិកតា នៅខេត្តឧត្តរមានជ័យ និងធ្វើអាជីវកម្មលក់ផ្ទះវិឡាចំនួន ១១(ដប់មួយ)វិឡា នៅខេត្តបន្ទាយមានជ័យ។ ដោយសារតែអាជីវកម្មហួសសមត្ថភាពរបស់កូនក្ដីខ្លួន ទើបកូនក្ដីខ្លួនបានខ្ចីប្រាក់ពីដើមចោទជាបន្តបន្ទាប់ ដោយឈ្មោះ [redacted] គុយហេង ត្រូវជាប្ដីរបស់ដើមចោទបានអះអាងថា ឲ្យកូនក្ដីខ្លួនខ្ចីលុយពីប្រពន្ធគាត់ឈ្មោះ [redacted] សុខគីម ទៅដើម្បីយកលុយនឹងទៅទិញដីរកស៊ីចូលហ៊ុនជុំគ្នា។ រហូតដល់សព្វថ្ងៃនេះ ការរកស៊ីជាមួយគ្នានេះ ក៏លេងដំណើរការទៅមុខ ហើយភាគីដែលជាកូនក្ដីខ្លួនសុំធ្វើការជម្រះបញ្ជីដើម្បីធ្វើការបែងចែកទ្រព្យសកម្ម និងទ្រព្យអកម្មជុំគ្នា។

កូនក្ដីខ្លួនទទួលស្គាល់ថា បានផ្ដិតមេដៃនៅលើកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំអចលនវត្ថុ និងមូលប្បទានបត្រទាំង ០៤(បួន)លើក និងបានទទួលប្រាក់ពីដើមចោទប្រាកដមែន។ ប្រាក់នេះខ្ចីដើម្បីយកទៅកាន់កងនៅក្នុងក្រុមហ៊ុនដែលរកស៊ីចូលហ៊ុនជាមួយគ្នា។ ប៉ុន្តែកូនក្ដីខ្លួនមិនទទួលស្គាល់នូវការទាមទាររបស់ដើមចោទទេ ដោយមូលហេតុកាលពីឆ្នាំ២០២០ កូនក្ដីខ្លួន និងដើមចោទបានទំនាក់ទំនងរកស៊ីដើម្បីស្វែងរកប្រាក់ចំណេញ ដោយមានការអះអាងពីដើមចោទ ជាហេតុនាំឲ្យកូនក្ដីខ្លួនចាប់ផ្ដើមដាក់ទុនរួមគ្នាក្នុងការទិញអចលនទ្រព្យ(ដីកសិកម្ម, ដីលំនៅដ្ឋាន, ដីអភិវឌ្ឍន៍ និងឧបករណ៍កសិកម្ម) ដោយការចំណាយទុនប្រមាណជា ៥០០.០០០$(ប្រាំរយពាន់ដុល្លារអាមេរិក)។ ក្នុងឆ្នាំ២០២១ ដោយសារការវិនិយោគលើអចលនទ្រព្យធ្វើឲ្យមានការបង់ខាតប្រមាណជា ២៥០.០០០$(ពីររយហាសិបពាន់ដុល្លារអាមេរិក) និងខាតបង់លើវិស័យកសិកម្មប្រមាណជា ២០០.០០០$(ពីររយពាន់ដុល្លារអាមេរិក) ទើបឈ្មោះ [redacted] គុយហេង ត្រូវជាប្ដីរបស់ដើមចោទបានអះអាងថា ឲ្យកូនក្ដីខ្លួនខ្ចីលុយពីប្រពន្ធគាត់ឈ្មោះ [redacted] សុខគីម ដើម្បីយកទៅដាក់វិនិយោគលើការអភិវឌ្ឍអចលនវត្ថុនៅខេត្តបន្ទាយមានជ័យ និងបណ្ដាខេត្តនានាផ្សេងៗទៀត កូនក្ដីខ្លួនហេតុតែចង់ស្រោចស្រង់ដើមទុនត្រឡប់មកវិញ ក៏បានសហការជាមួយដើមចោទជាកិច្ចសន្យាផ្ទាល់មាត់ ក្នុងការបែងចែកចំណែកស្មើគ្នា ប៉ុន្តែដោយសារតែកូនក្ដីខ្លួនបានបង់ខាតដើមទុនជាច្រើនមក ហើយពុំមានលទ្ធភាពក្នុងការបណ្ដាក់ទុនទិញអចលនទ្រព្យបន្ថែម ដើមចោទអះអាងធានាលើការទិញទាំងស្រុងដោយកំណត់តម្លៃពាក់កណ្ដាលនៃថ្លៃដីដាក់ជាកិច្ចសន្យាបញ្ចាំ ដោយតម្រូវឲ្យកូនក្ដីខ្លួនដាក់ប្រាតិភោគអចលនទ្រព្យ និងសែក។ បន្ទាប់មករាល់ការវិនិយោគលើអចលនទ្រព្យដើមចោទតែងតែទាមទារឲ្យកូនក្ដីខ្លួនបង្កើតកិច្ចសន្យាបញ្ចាំ រហូតដល់០៤លើក មានដូចខាងក្រោម:

១-កិច្ចសន្យាបញ្ចាំមូលប្បទានប័ត្រ របស់ធនាគារស្ថាបនាលេខ ៨០៣៦១៩ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។

២-កិច្ចសន្យាបញ្ចាំមូលប្បទានប័ត្រ របស់ធនាគារស្ថាបនាលេខ ៦៥៧៨០៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២។

៣-កិច្ចសន្យាបញ្ចាំមូលប្បទានបត្រ របស់ធនាគារស្ថាបនាលេខ ៦៥៧៨០៥ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។



Scanned with CamScanner

៤-កិច្ចសន្យាបញ្ចាំមូលប្បទានបត្រ របស់ធនាគារស្ថាបនាលេខ ៨០៣៦២១ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២។

ចំពោះភស្តុតាង គឺកូនក្តីខ្លួនមានជាកិច្ចសន្យាទាំង ០៤(បួន)ខាងលើ ដោយក្នុងកិច្ចសន្យានេះ បញ្ជាក់ថា ជាកិច្ចសន្យាដែលផ្ទុយនឹងច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ត្រង់មាត្រា ៦ និងមាត្រា ១០ និងមាត្រា ១៣២ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ព្រោះមូលប្បទានបត្រមិន មែនជាកម្មវត្ថុនៃការបញ្ចាំទេ ការបញ្ចាំអាចប្រព្រឹត្តទៅបានលុះតែជាវត្ថុដែលអាចកាន់កាប់លើវត្ថុនោះដោយ ចំពោះ។ ហេតុនេះ កិច្ចសន្យា ដែលខុសច្បាប់យើងមិនអាចយកមកអនុវត្តបានទេ។

ភស្តុតាងដែលជា កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានទឹកប្រាក់ ចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក), លិខិតទូទាត់សងប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ និងប្រតិបត្តិការផ្ទេរប្រាក់វិនិយោគ គឺបញ្ជាក់បានថាកូនក្តីខ្លួនបានសងចំនួន ៥០.០០០$(ហាសិបពាន់ ដុល្លារអាមេរិក) រួមនឹងការប្រាក់ ១០.០០០$(ដប់ពាន់ដុល្លារអាមេរិក) ទៅឲ្យដើមចោទរួចហើយ។ ដោយ ឡែកកិច្ចសន្យាផ្សេងទៀត កូនក្តីខ្លួនទទួលស្គាល់ថាពិតជាបានផ្តិតមេដៃលើកិច្ចសន្យានោះមែន ប៉ុន្តែមិន ទទួលស្គាល់នូវការទាមទាររបស់ដើមចោទនោះទេ។ ចំពោះប្រាក់ទាំងអស់ដែលមាននៅក្នុងកិច្ចសន្យាគឺ កូនក្តីខ្លួនពិតជាបានទទួលពីដើមចោទមែន។

យោងតាមអង្គហេតុ និងអង្គច្បាប់ខាងលើ ឃើញថា កូនក្តីខ្លួន និងដើមចោទបានរកស៊ីចូលហ៊ុនគ្នា ទិញអចលនទ្រព្យប្រាកដមែន ជាគោលការណ៍ការចូលហ៊ុនគ្នារកស៊ីអ្វីមួយនៅពេលបែកគ្នាភាគីដែលចូល ហ៊ុនគ្នារកស៊ី ទោះបីគ្មានកិច្ចសន្យាជាលាយលក្ខណអក្សរក្តី ឬកិច្ចសន្យាដោយផ្ទាល់មាត់ក៏ត្រូវបានយកជា បានការ។ ចំណែកកិច្ចសន្យាបញ្ចាំទាំង ០៤ខាងលើជាកិច្ចសន្យាដែលបង្កើតឡើងដោយខុសច្បាប់។

ហេតុនេះ កូនក្តីខ្លួនសុំឲ្យតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ និងស្នើសុំឲ្យធ្វើ ការជម្រះបញ្ជីតាមផ្លូវច្បាប់ ដើម្បីយកធ្វើការបែងចែកទ្រព្យជាមួយនឹងកូនក្តីខ្លួនសិន និងសុំមោឃភាពនូវ កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំទាំង ០៤(បួន)ខាងលើ។

**ឈ្មោះ [redacted] សំបូរ ជាចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា៖**

ខ្លួនសុំច្រានចោលការទាមទាររបស់ដើមចោទដែលមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ដោយសារតែដំបូងខ្លួន និងដើមចោទបានរកស៊ីចូលហ៊ុនជាមួយគ្នាក្នុងការទិញលក់អចលនវត្ថុ។ ហើយនៅពេលទិញអចលនវត្ថុចុងក្រោយប៉ះដីដែលមានវិវាទ ទើបធ្វើឲ្យខ្លួនគ្មានលទ្ធភាព ក៏បានខ្ចីប្រាក់ពី ដើមចោទ ដោយបានដាក់បញ្ចាំនូវអចលនទ្រព្យ និងមូលប្បទានបត្រ ដើម្បីយកទៅដាក់ទុនស្តារអាជីវកម្ម ឡើងវិញ។

ចំពោះកិច្ចសន្យាបញ្ចាំចំនួន០៤(បួន)លើក មានទឹកប្រាក់សរុបចំនួន ៣៥៦.០៧០$(បីរយហា សិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) ដែលដើមចោទបានលើកឡើងខាងលើនេះ ខ្លួនពិតជាបានព្រម ព្រៀងបង្កើតកិច្ចសន្យានេះជាមួយគាត់ប្រាកដមែន និងបានដាក់តម្កល់មូលប្បទានបត្រ ០៤(បួន)ជាមួយ នឹងគាត់។ ខ្លួនស្នើសុំទុកពេលដើម្បីធ្វើការទូទាត់ទ្រព្យសកម្ម និងទ្រព្យអកម្ម ដែលខ្លួន និងដើមចោទ បានចូលហ៊ុនជាមួយ ដោយធ្វើការជម្រះបញ្ជីជាមួយគ្នាសិនថា នៅសល់ប៉ុន្មាន ខ្វះប៉ុន្មាន បានខ្លួននឹងធ្វើ ការទូទាត់ប្រាក់ទៅឲ្យដើមចោទនៅពេលក្រោយ។



Scanned with CamScanner

## ការសំអាងហេតុ

ពាក្យបណ្តឹងអង្គសេចក្តី ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ របស់ដើមចោទ តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ៩ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ, អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ រួមនឹងការពិនិត្យភស្តុតាងជាឯកសារដែលមានក្នុងសំណុំរឿងឃើញថា:

### ក-ការវិនិច្ឆ័យចំពោះចំណុចវិវាទ

**តើការទាមទារប្រាក់សរុបចំនួន ៣៥៦.០៧០$(បីរយហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) របស់ដើមចោទចំពោះចុងចម្លើយត្រឹមត្រូវដែរ ឬទេ?**

ដើមចោទបានអះអាងថា ប្រាក់សរុបចំនួន ៣៥៦.០៧០$(សាមសិបប្រាំម៉ឺនប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) គឺជាប្រាក់ដើមដែលចុងចម្លើយនៅជំពាក់ ដោយសំអាងលើភស្តុតាងជាឯកសារមាន កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ និងកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។ នៅត្រង់ការទាមទារនេះ ចុងចម្លើយទទួលស្គាល់ថាបានចុះកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំជាមួយដើមចោទ ប៉ុន្តែមិនទទួលថាបានជំពាក់ប្រាក់ដើមចោទនូវចំនួន ៣៥៦.០៧០$ (សាមសិបប្រាំម៉ឺនប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក)នោះទេ ព្រោះចុងចម្លើយបានសងប្រាក់ទៅឲ្យដើមចោទបានចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក)រួចហើយ ដោយសំអាងលើកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, លិខិតទូទាត់សងប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ និងប្រតិបត្តិការផ្ទេរប្រាក់ទូទាត់។ ការខ្ចីប្រាក់ដើមចោទនេះ ដើម្បីយកទៅចូលហ៊ុន វិនិយោគដី និងផ្ទះជាមួយដើមចោទ ដូចមាននៅក្នុងភស្តុតាង ជារូបភាពផ្ទះវិឡានៅខេត្តបន្ទាយមានជ័យ, ប្រតិបត្តិការផ្ទេរប្រាក់វិនិយោគ, គ្រុបតេឡេក្រាម និងគម្រោងផ្ទះគំរូ។

តាមការអះអាងខាងលើ តុលាការពិនិត្យឃើញថា នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ និងកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ឃើញថា ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាលើកម្ចីដោយមានទឹកប្រាក់សរុបចំនួន ៣៥៦.០៧០$(បីរយហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក)។ ដោយឡែក កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានទឹកប្រាក់កម្ចីចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក), លិខិតទូទាត់សងប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ និងប្រតិបត្តិការផ្ទេរប្រាក់ទូទាត់ ឃើញថា មិនមានពាក់ព័ន្ធនឹងប្រាក់កម្ចីនៃកិច្ចសន្យាខាងលើនេះទេ។

ដូច្នេះ តុលាការទទួលស្គាល់ថាប្រាក់ចំនួន ៣៥៦.០៧០$(បីរយហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) ជាប្រាក់ដើមដែលចុងចម្លើយនៅជំពាក់ដើមចោទ។

### ខ-ការវិនិច្ឆ័យចំពោះការទាមទារ

ខ-១-ដើមចោទប្តឹងទាមទារឲ្យចុងចម្លើយសងប្រាក់ដើមដែលប្រាក់ដើមរួមមាន:



Scanned with CamScanner

ខ-១-១-ប្រាក់ដើមចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១)។

តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ឃើញថា ភាគីដើមចោទជាអ្នកឲ្យខ្ចី និងភាគីចុងចម្លើយជាអ្នកខ្ចីបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ១០០.០០០$ (មួយរយពាន់ដុល្លារអាមេរិក) ដោយខ្ចីក្នុងរយៈពេល០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ តាមអត្រាការប្រាក់ ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់ចំនួន ២.៥០០$(ពីរពាន់ប្រាំរយដុល្លារអាមេរិក)ក្នុងមួយខែ។ ដោយចុងចម្លើយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ទើបធ្វើឲ្យប្រាក់ដើមដែលចុងចម្លើយនៅជំពាក់មានចំនួន ១០០.០០០$ (មួយរយពាន់ដុល្លារអាមេរិក) ដដែល។

ខ-១-២-ប្រាក់ដើមចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក)(កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១)។

កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ឃើញថា ភាគីដើមចោទជាអ្នកឲ្យខ្ចី និងភាគីចុងចម្លើយជាអ្នកខ្ចីបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) ដោយខ្ចីក្នុងរយៈពេល ០២(ពីរ)ខែ គិតចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ តាមអត្រាការប្រាក់ ៣%(បីភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់ចំនួន ៤.៥០០$(បួនពាន់ប្រាំរយដុល្លារអាមេរិក)ក្នុងមួយខែ។ ដោយចុងចម្លើយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ទើបធ្វើឲ្យប្រាក់ដើមដែលចុងចម្លើយនៅជំពាក់មានចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) ដដែល។

ខ-១-៣-ប្រាក់ដើមចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក)(កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២)។

កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ឃើញថា ភាគីដើមចោទជាអ្នកឲ្យខ្ចី និងភាគីចុងចម្លើយជាអ្នកខ្ចីបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) ដោយខ្ចីក្នុងរយៈពេល ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ តាមអត្រាការប្រាក់ ២,៥០%(ពីរក្បៀសហាសិបភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់ចំនួន ១.២៥០$(មួយពាន់ពីររយហាសិបដុល្លារអាមេរិក)ក្នុងមួយខែ។ ដោយចុងចម្លើយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ទើបធ្វើឲ្យប្រាក់ដើមដែលចុងចម្លើយនៅជំពាក់មានចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) ដដែល។

១-ក-៤-ប្រាក់ដើមចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២)។

កិច្ចសន្យាខ្ចីប្រាក់ ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ឃើញថា ភាគីដើមចោទជា អ្នកឲ្យខ្ចី និងភាគីចុងចម្លើយជាអ្នកខ្ចីបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) ដោយខ្ចីក្នុងរយៈពេល ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១២ រហូតដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ តាមអត្រាការប្រាក់ ២,៥០%(ពីរក្បៀសហាសិប



Scanned with CamScanner

ភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់ចំនួន ១.៤០១,៧៥$(មួយពាន់បួនរយមួយដុល្លារអាមេរិក និងចិតសិបប្រាំសេន)ក្នុងមួយខែ។ ដោយចុងចម្លើយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ទើបធ្វើឲ្យប្រាក់ដើមដែលចុងចម្លើយនៅជំពាក់មានចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) ដដែល។

ចុងចម្លើយទទួលស្គាល់ថាបានបង្កើតកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំខាងលើ ប៉ុន្តែមិនទទួលស្គាល់នូវប្រាក់ដែលដើមចោទទាមទារនោះទេ ដោយសំអាងថាប្រាក់ដែលខ្ចីនោះបានសងចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក)រួចហើយ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, លិខិតទូទាត់សងប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ និងប្រតិបត្តិការផ្ទេរប្រាក់ទូទាត់។ ការខ្ចីប្រាក់នេះដើម្បីយកទៅដាក់ហ៊ុនវិនិយោគដី និងផ្ទះវិឡាជាមួយដើមចោទ។

តុលាការពិនិត្យឃើញថា ដើមចោទជាភាគីអ្នកឲ្យខ្ចី និងចុងចម្លើយជាភាគីអ្នកខ្ចីពិតជាបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីបរិភោគ ស្របតាមបញ្ញត្តិមាត្រា ៥៧៨ និងមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី។ម្យ៉ាងទៀត បើពិនិត្យលើពេលវេលានៃការបង់ការប្រាក់ និងអំឡុងពេលនៃការអនុវត្តកិច្ចសន្យានៅក្នុងកិច្ចសន្យាខ្ចីបរិភោគខាងលើត្រូវបានបញ្ចប់ហើយ ប៉ុន្តែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ប្រាក់ដើម និងបង់ការប្រាក់ទៅឲ្យដើមចោទ ស្របតាមបញ្ញត្តិមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី នោះទេ។ ដោយឡែក បើតាមពិនិត្យលើលិខិតទូទាត់សងប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ដែលបញ្ជាក់ថាឈ្មោះ [redacted] សំបាន បានសងប្រាក់ទៅឲ្យដើមចោទចំនួន ៦០.០០០$(ហុកសិបពាន់ដុល្លារអាមេរិក) ជំនួសចុងចម្លើយដែលបានខ្ចីនៅក្នុងកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ឃើញថាភស្តុតាងនេះមិនមានគោលដៅបញ្ជាក់នូវការទូទាត់សងប្រាក់ដែលមាននៅកិច្ចសន្យាដែលដើមចោទទាមទារប្រាក់ពីចុងចម្លើយនោះទេ។

ដូច្នេះ តុលាការគប្បីសម្រេចតាមការទាមទាររបស់ដើមចោទ។

**ខ-២-ដើមចោទទាមទារឲ្យចុងចម្លើយសងការប្រាក់នៃប្រាក់ដើមដែលការប្រាក់មានដូចខាងក្រោម:**

**ខ-២-១-ការប្រាក់ចំនួន ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១០០.០០០$ (មួយរយពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។**

តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ នៅត្រង់ប្រការ២ ឃើញថាដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាកំណត់យកការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ២.៥០០$(ពីរពាន់ប្រាំរយដុល្លារអាមេរិក)ក្នុងមួយខែ ហើយចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ចុងចម្លើយបានខកខានក្នុងការសងការប្រាក់មកឲ្យដើមចោទ។

យោងតាមមាត្រា ៥៧៩, មាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី, ប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ និងប្រកាស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដែលអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់លើប្រាក់ឥណទានមិនឲ្យលើសពី ១៨%(ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

តុលាការយល់ឃើញថា ចុងចម្លើយបានព្រមព្រៀងគ្នាជាមួយដើមចោទ ក្នុងការកំណត់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ២.៥០០$(ពីរពាន់ប្រាំរយ



Scanned with CamScanner

ដុល្លារអាមេរិក)ក្នុងមួយខែ តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ប្រាកដមែន ប៉ុន្តែការប្រាក់ដែលបានកំណត់នេះ មានអត្រាការប្រាក់លើសពីការកម្រិតដែលច្បាប់បានកំណត់។ ហេតុនេះ ការប្រាក់ដែលជាភាគលើសពីកម្រិតនៃអត្រាការប្រាក់ត្រូវទុកជាមោឃៈ ស្របតាមបញ្ញត្តិមាត្រា ៥៨៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ហេតុដូច្នេះ តុលាការគប្បីសម្រេចបង្គាប់ឲ្យចុងចម្លើយសងការប្រាក់ទៅឲ្យចុងចម្លើយ តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ខ-២-២-ការប្រាក់ចំនួន ៣%(បីភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១៥០.០០០$ (មួយរយហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។**

តាមរយៈកិច្ចសន្យាខ្ចីប្រាក់,ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ នៅត្រង់ប្រការ២ ឃើញថាដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាកំណត់យកការប្រាក់តាមអត្រា ៣%(បីភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ៤.៥០០$(បួនពាន់ប្រាំរយដុល្លារអាមេរិក)ក្នុងមួយខែ ហើយចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ចុងចម្លើយបានខកខានក្នុងការសងការប្រាក់មកឲ្យដើមចោទ។

យោងតាមមាត្រា ៥៧៩, មាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី, ប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ និងប្រកាស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដែលអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហរិញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់លើប្រាក់ឥណទានមិនឲ្យលើសពី ១៨%(ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

តុលាការយល់ឃើញថា ចុងចម្លើយបានព្រមព្រៀងគ្នាជាមួយដើមចោទ ក្នុងការកំណត់ការប្រាក់តាមអត្រា ៣%(បីភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ៤.៥០០$(បួនពាន់ប្រាំរយដុល្លារអាមេរិក) ក្នុងមួយខែ តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រាកដមែន ប៉ុន្តែការប្រាក់ដែលបានកំណត់នេះ មានអត្រាការប្រាក់លើសពីការកម្រិតដែលច្បាប់បានកំណត់។ ហេតុនេះ ការប្រាក់ដែលជាភាគលើសពីកម្រិតនៃអត្រាការប្រាក់ត្រូវទុកជាមោឃៈ ស្របតាមបញ្ញត្តិមាត្រា ៥៨៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ហេតុដូច្នេះ តុលាការគប្បីសម្រេចបង្គាប់ឲ្យចុងចម្លើយសងការប្រាក់ទៅឲ្យចុងចម្លើយ តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ខ-២-៣-ការប្រាក់ចំនួន ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ៥០.០០០$ (ហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។**

តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ នៅត្រង់ប្រការ២ ឃើញថាដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាកំណត់យកការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ១.២៥០$(មួយពាន់ពីររយហាសិបដុល្លារអាមេរិក)ក្នុងមួយខែ ហើយចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ចុងចម្លើយបានខកខានក្នុងការសងការប្រាក់មកឲ្យដើមចោទ។



Scanned with CamScanner

យោងតាមមាត្រា ៥៧៩, មាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី, ប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ និងប្រកាស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដែលអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់លើប្រាក់ឥណទានមិនឲ្យលើសពី ១៨%(ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

តុលាការយល់ឃើញថា ចុងចម្លើយបានព្រមព្រៀងគ្នាជាមួយដើមចោទ ក្នុងការកំណត់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ១.២៥០$(មួយពាន់ពីររយហាសិបដុល្លារអាមេរិក)ក្នុងមួយខែ តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ប្រាកដមែន ប៉ុន្តែការប្រាក់ដែលបានកំណត់នេះ មានអត្រាការប្រាក់លើសពីការកម្រិតដែលច្បាប់បានកំណត់។ ហេតុនេះ ការប្រាក់ដែលជាភាគលើសពីកម្រិតនៃអត្រាការប្រាក់ត្រូវទុកជាមោឃៈ ស្របតាមបញ្ញត្តិមាត្រា ៥៨៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ហេតុដូច្នេះ តុលាការគប្បីសម្រេចបង្គាប់ឲ្យចុងចម្លើយសងការប្រាក់ទៅឲ្យចុងចម្លើយ តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ខ-២-១-ការប្រាក់ចំនួន ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ៥៦.០៧០$ (ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។**

តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ នៅត្រង់ប្រការ២ ឃើញថា ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាកំណត់យកការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ) ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ១.៤០១,៧៥$(មួយពាន់បួនរយមួយដុល្លារអាមេរិក និងចិតសិបប្រាំសេន)ក្នុងមួយខែ ហើយចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ចុងចម្លើយបានខកខានក្នុងការសងការប្រាក់មកឲ្យដើមចោទ។

យោងតាមមាត្រា ៥៧៩, មាត្រា ៥៨៤ និងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី, ប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ និងប្រកាស ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ដែលអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់លើប្រាក់ឥណទានមិនឲ្យលើសពី ១៨%(ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

តុលាការយល់ឃើញថា ចុងចម្លើយបានព្រមព្រៀងគ្នាជាមួយដើមចោទ ក្នុងការកំណត់ការប្រាក់តាមអត្រា ២,៥%(ពីរក្បៀសប្រាំភាគរយ)ក្នុងមួយខែ គិតជាទឹកប្រាក់មានចំនួន ១.៤០១,៧៥$(មួយពាន់បួនរយមួយដុល្លារអាមេរិក និងចិតសិបប្រាំសេន)ក្នុងមួយខែ តាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ប្រាកដមែន ប៉ុន្តែការប្រាក់ដែលបានកំណត់នេះ មានអត្រាការប្រាក់លើសពីការកម្រិតដែលច្បាប់បានកំណត់។ ហេតុនេះ ការប្រាក់ដែលជាភាគលើសពីកម្រិតនៃអត្រាការប្រាក់ត្រូវទុកជាមោឃៈ ស្របតាមបញ្ញត្តិមាត្រា ៥៨៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

ហេតុដូច្នេះ តុលាការគប្បីសម្រេចបង្គាប់ឲ្យចុងចម្លើយសងការប្រាក់ទៅឲ្យចុងចម្លើយ តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ នៃប្រាក់ដើមចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ខ-៣-ដើមចោទទាមទារឲ្យចុងចម្លើយសងថ្លៃខូចខាត និងសំណងជម្ងឺចិត្តចំនួន ៥០.០០០.០០០៛ (ហាសិបលានរៀល)។**

ដើមចោទអះអាងថា ចុងចម្លើយជាអ្នកមានកំហុសដែលមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការទូទាត់ប្រាក់មកឲ្យដើមចោទធ្វើឲ្យដើមចោទខាតបង់ពេលវេលា ខាតបង់សោហ៊ុយក្នុងការចំណាយដើម្បីដំណើរការរឿងក្តីនេះ។ តុលាការយល់ឃើញថា ភាគីចុងចម្លើយ គឺពិតជាមានកំហុសដែលមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ និងកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ ដែលត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតរបស់ដើមចោទ ដែលក្នុងនោះរួមមានសំណងជម្ងឺចិត្ត។

ដូចនេះ យោងតាមមាត្រា ៣៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី តុលាការទទួលស្គាល់ថា ការខូចខាតរបស់ដើមចោទដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ច គឺជាសំណងនៃការខូចខាត ដែលគប្បីតុលាការសម្រេចឲ្យ ចុងចម្លើយសងប្រាក់ដែលជាសំណងនៃការខូចខាត ឲ្យទៅដើមចោទដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច ទំហំនៃការខូចខាត និងជីវភាពរបស់ចុងចម្លើយ ស្របតាមបញ្ញត្តិមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី។

**ខ-៤-សុំអនុវត្តជាបណ្ដោះអាសន្នចំណុចទី១ (១-១, ១-២, ១-៣ និង១-៤)**

ដោយសារតែចុងចម្លើយមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា និងដើម្បីងាយស្រួលនៅក្នុងការចាត់ចែងនូវនីតិវិធីបន្តទៀត ម្យ៉ាងទៀតកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ និងកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ មានភាពច្បាស់លាស់ និងដើម្បីកុំឲ្យមានការអូសបន្លាយនីតិវិធីតទៅមុខទៀត។ តុលាការយល់ឃើញថា ការប្រកាសសាលក្រមឲ្យអនុវត្តជាបណ្ដោះអាសន្ននោះ ជាការចាំបាច់ចំពោះការទាមទារដែលមានសិទ្ធិលើទ្រព្យសម្បត្តិ។

ដូច្នេះ ដើម្បីជៀសវាងការអូសបន្លាយពេលវេលា និងជាការចាំបាច់តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការចេញសាលក្រមសម្រេចប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្នលើការទាមទារចំណុចទី១ របស់ដើមចោទនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនេះ។

**គ-បន្ទុកប្រាក់ប្រដាប់ក្ដី**

យោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាក់ក្ដីជារបស់ភាគីចាញ់ក្ដី។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឲ្យភាគីចាញ់ក្ដីជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី។

**សេចក្ដីសម្រេចបញ្ចប់**

១-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ដើមមកឲ្យដើមចោទ ដែលប្រាក់ដើមរួមមាន:

១-១-ប្រាក់ចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១)។



Scanned with CamScanner

១-២-ប្រាក់ចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១)។

១-៣-ប្រាក់ចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២)។

១-៤-ប្រាក់ចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) (កិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២)។

២-បង្គាប់ឲ្យចុងចម្លើយសងការប្រាក់មកឲ្យដើមចោទ ដែលការប្រាក់រួមមាន:

២-១-ការប្រាក់តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ១០០.០០០$(មួយរយពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-២-ការប្រាក់តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៥០.០០០$(មួយរយហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-៣-ការប្រាក់តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ៥០.០០០$(ហាសិបពាន់ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

២-៤-ការប្រាក់តាមអត្រា ១,៥%(មួយក្បៀសប្រាំភាគរយ)ក្នុងមួយខែ លើប្រាក់ដើមចំនួន ៥៦.០៧០$(ហាសិបប្រាំមួយពាន់ចិតសិបដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣-បង្គាប់ឲ្យចុងចម្លើយសងសំណងការខូចខាត និងសំណងជម្ងឺចិត្តចំនួន ២៥.០០០.០០០៛(ម្ភៃប្រាំលានរៀល) មកឲ្យដើមចោទ ការទាមទារលើសពីនេះបដិសេធចោល។

៤-សាលក្រមនេះប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី១(១-១, ១-២, ១-៣ និង១-៤) នៃសេចក្តីសម្រេចបញ្ចប់ខាងលើ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣។ ក្នុងករណីភាគីមិនសុខចិត្តនឹងសាលក្រមនេះអាចប្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និង ត្រា: **ស៊ាង ណារ៉ា**

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner